**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**សូមគោរពជូន**

**ឯកឧត្តម សាយ ឈុំ**

**ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា**

*ឯកឧត្តមប្រធាន,*

ក្នុងខណៈពេលដែលឯកឧត្តមប្រធានត្រូវបានជាប់ឆ្នោតជា ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥តទៅនោះ ខ្ញុំក្នុងនាមថ្នាក់ដឹកនាំ និង មន្ត្រីរាជការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានសេចក្តីរំភើបរីករាយឥតឧបមា សូមសម្តែងនូវអំណរសាទរយ៉ាងកក់ក្តៅជូនឯកឧត្តមប្រធាន ។

យើងខ្ញុំមានជំនឿយ៉ាងមុតមាំថា ក្រោមការដឹកនាំរបស់ឯកឧត្តមប្រធាន ព្រឹទ្ធសភានឹងរឹងរិតតែមានការរីកចម្រើនថែមទៀត ព្រមទាំងចូលរួមអភិវឌ្ឍប្រទេសជាតិ តាមតួនាទីជាស្ថាប័ននីតិបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា យ៉ាងពិតប្រាកដ។

សូមជូនពរឯកឧត្តមប្រធានមានសុខភាពល្អ និង ទទួលបាននូវជោគជ័យក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមដើម្បីបម្រើជាតិមាតុភូមិរបស់ឯកឧត្តមប្រធាន។

សូមឯកឧត្តមប្រធានទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**

**និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

ទៀង_មូលី

អាសយដ្ឋានៈ អគារលេខ ១៦ ផ្លូវលេខ ២៧១ កែង ១៥០ សង្កាត់ទឹកល្អក់ II ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារ (៨៥៥-២៣) ៨៨៥ ១២៩